ក្រុមសៀវភៅការរុករកឃើញ®

# ការប្រកាន់ខ្ជាប់នូវសេចក្តីជំនឿ

## ការលះបង់ដើម្បីដើរតាមព្រះគ្រីស្ទ



និពន្ធដោយ : Chen Pei Fen



*សេចក្ដីផ្ដើម*

# ការប្រកាន់ខ្ជាប់នូវសេចក្ដីជំនឿ

ការលះបង់ ដើម្បីដើរតាមព្រះគ្រីស្ទ

ម្ដាយ **របស់ខ្ញុំមានការពិបាកចិត្ត។** ខ្ញុំដឹងច្បាស់ថា គាត់មិនសប្បាយចិត្ត ព្រោះគាត់បានព្យាយាមបញ្ចុះបញ្ចូលខ្ញុំ ឲ្យលះបង់សេចក្ដីជំនឿថ្មីមួយ ដែលខ្ញុំទើបតែបានទទួលយក។ គាត់ថា “កូនក្លាយជាគ្រីស្ទានហើយ តើកូនដឹងថា កូនបានធ្វើអ្វីខុសខ្លះ? កូនបានបោះបង់ប្រពៃណីរបស់គ្រួសារ។ ឪពុករបស់កូនមានការខកចិត្តណាស់ ដែលមិនអាចគ្រប់គ្រងគ្រួសាររបស់យើង ឲ្យបានល្អ។” ទន្ទឹមនឹងនោះ ឪពុកខ្ញុំមានការឈឺចាប់ក្នុងចិត្ត យ៉ាងស្ងាត់ស្ងៀម។ គាត់គេងមិនលក់អស់រយៈពេលបីបួនយប់ហើយ ព្រោះគាត់គិតថា កូនស្រីគាត់បានបោះបង់ចោលប្រពៃណីគ្រួសារ ហើយដើរតាមសាសនា “បរទេស”។

កាលនោះ ខ្ញុំមានអាយុ១៥ឆ្នាំ ហើយទើបតែបានយាងព្រះយេស៊ូវគ្រីស្ទ ចូលគង់ក្នុងចិត្តខ្ញុំ។ ខ្ញុំបានធ្វើការសម្រេចចិត្តទទួលជឿព្រះអង្គ ដោយចិត្តរីករាយជាពន់ពេក ដោយដឹងថា ខ្ញុំបានធ្វើនូវរឿងដ៏ចាំបាច់មួយ។ ប៉ុន្តែ ពេលនោះជីវិតខ្ញុំក៏បានជួបព្យុះភ្លៀង។ ខ្ញុំមានការឈឺចាប់ ពេលដែលបានដឹងថា ឪពុកម្ដាយខ្ញុំមានការពិបាកចិត្ត និងខកចិត្តយ៉ាងខ្លាំងចំពោះខ្ញុំ។

ខ្ញុំក៏ចាប់ផ្ដើមគិតអំពីមូលហេតុដែលខ្ញុំបានក្លាយជាគ្រីស្ទបរិស័ទ ហើយឆ្ងល់ថា តើការសម្រេចចិត្តនេះត្រឹមត្រូវឬទេ។ តើខ្ញុំជាកូនមិនល្អឬ? តើខ្ញុំគួរតែបន្តប្រកាន់ខ្ជាប់តាមជំនឿថ្មីរបស់ខ្ញុំឬ? តើខ្ញុំពិតជាចង់ក្លាយជាសិស្សរបស់ព្រះយេស៊ូវឬ? តើខ្ញុំបានត្រៀមខ្លួនបោះបង់ចោលសេចក្ដីស្រឡាញ់ និងការគាំទ្ររបស់ក្រុមគ្រួសារខ្ញុំឬទេ? តើការសម្រេចចិត្តនេះ ត្រឹមត្រូវឬអត់?

ក្នុងបទគម្ពីរ លូកា ១៤:២៦ ព្រះយេស៊ូវបានមានបន្ទូលថា “បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្ដាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ”។

រឿងនេះហាក់ដូចជាបញ្ហាប្រឈមដែលខ្ញុំកំពុងជួបប្រទះ។ ពេលដែលម្ដាយរបស់ខ្ញុំដាក់សម្ពាធឲ្យខ្ញុំផ្លាស់ប្ដូរគំនិត ខ្ញុំមានអារម្មណ៍ថា ហាក់ដូចជាត្រូវធ្វើការសម្រេចចិត្តជ្រើសរើសរវាងព្រះយេស៊ូវ និងឪពុកម្ដាយរបស់ខ្ញុំ។ បើខ្ញុំចង់ស្ដាប់បង្គាប់ឪពុកម្ដាយខ្ញុំ ហើយមិនចង់ឲ្យពួកគាត់ពិបាកចិត្ត នោះខ្ញុំត្រូវតែបោះបង់សេចក្ដីជំនឿរបស់ខ្ញុំ។ ប៉ុន្តែ ព្រះយេស៊ូវហាក់ដូចជាកំពុងតែប្រាប់ខ្ញុំ ឲ្យ “ស្អប់” ឪពុកម្ដាយខ្ញុំ។ តើតាមន័យត្រង់ ព្រះអង្គពិតជាសព្វព្រះទ័យឲ្យខ្ញុំស្អប់ពួកគាត់មែនឬ? តើខ្ញុំអាចបន្តស្រឡាញ់ឪពុកម្ដាយខ្ញុំ ដោយមិនដើរតាមព្រះអង្គបានឬទេ?

តើអ្នកកំពុងតែជួបបញ្ហាស្រដៀងនឹងខ្ញុំដែរឬទេ? តើក្រុមគ្រួសារ ឬសហគមន៍របស់អ្នក បានប្រឆាំងនឹងជំនឿ ដែលអ្នកមានចំពោះព្រះជាម្ចាស់ឬទេ? តើអ្នកកំពុងតែស្ថិតនៅក្រោមសម្ពាធ ដែលបង្ខំឲ្យអ្នកវិលត្រឡប់ទៅរកជំនឿសាសនាដែលអ្នកធ្លាប់មានកាលពីមុខឬ ហើយតើអ្នកឆ្ងល់ទេថា សេចក្ដីជំនឿនេះសក្ដិសមនឹងឲ្យអ្នកទទួលរងការឈឺចាប់យ៉ាងនេះឬ?

សូមអនុញ្ញាតឲ្យខ្ញុំចែកចាយទីបន្ទាល់នៃជីវិតខ្ញុំ ជាមួយអ្នក ដូចតទៅ :

# មាតិកា

*ទី១*

*ការជឿព្រះបន្ទូលសន្យា ....................................................5*

*ទី២*

*ការជម្នះបញ្ហាប្រឈម ......................................................11*

*ទីបី*

*ការជឿទុកចិត្តចំពោះការធានា ............................................15*

*ទី៤*

*ការស្វែងយល់អំពីជំនឿឲ្យបានច្បាស់ .....................................19*

*ទី៥*

*ការគោរពប្រតិបត្តិដល់ឪពុកម្តាយ ..........................................24*

ទី៦

ការរស់នៅ ក្នុងសេចក្តីសង្ឃឹម និងការទុកចិត្ត...............................*28*

*សេចក្តីបន្ថែមចុងក្រោយ.................................................... 31*

EDITORS: Tim Gustafson, J.R. Hudberg, Leslie Koh, Kahn Hui Neon, Peggy Willison
COVER IMAGE© iStock.com / Franckreporter
COVER DESIGN: Stan Myers
INTERIOR DESIGN: Steve Gier
INTERIOR IMAGES: (p.1) © iStock.com / Franckreporter; (p.5) Lekyu via Freeimages.com; (p.11) Unsplash via Pixabay.com; (p.15) Lumix2004 via Pixabay.com;

( p.19) Congerdesign via Pixabay.com; (p.23) Alexandr Pirogov via Pixabay.com;

( p.27) Barbara Jackson via Pixabay.com (p.23) Alexandr Pirogov via Pixabay.com

All Scripture quotations, unless otherwise indicated, are taken from THE HOLY BIBLE, NEW INTERNATIONAL VERSION®, NIV® Copyright © 1973, 1978, 1984, 2011 by Biblica, Inc.® Used by permission. All rights reserved worldwide.

© 2017 Our Daily Bread Ministries, Grand Rapids, MI
All rights reserved.



*ទី១*

# ការជឿព្រះបន្ទូលសន្យា

*"គេក៏ប្រាប់គាត់ថា ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះ ហើយ ព្រមទាំងពួកគ្រួសារលោកផង"- កិច្ចការ ១៦:៣១*

ខ្ញុំ **បានចាប់កំណើត**ក្នុងគ្រួសារចិនសឹង្ហបូរី ដែលប្រកាន់ខ្ជាប់តាមប្រពៃណីចិន។ ឪពុកម្ដាយខ្ញុំជាកូនចៅជំនាន់ក្រោយរបស់ អំបូរហាក់កា ដែលស្ថិតក្នុងចំណោមក្រុម ដែលប្រើក្រៀមភាសាចិនសំខាន់ៗ។ យើងបានចម្រើនវ័យធំឡើង ដោយទទួលការបង្រៀនឲ្យថ្វាយបង្គំព្រះរបស់ជនជាតិចិន ដូចគ្រួសារចិនភាគច្រើន។ យើងក៏បានដុតធូប និងសែនចំណីអាហារ ដល់បុព្វបុរសរបស់យើង ដើម្បីបំពេញតម្រូវការរបស់ពួកគេ នៅក្នុងស្ថានមនុស្សស្លាប់។ គេបានចាត់ទុកជំនឿ និងការអនុវត្តន៍ទាំងនេះ យ៉ាងទូលំទូលាយថាជា "អត្តសញ្ញាណរបស់ជនជាតិចិន" ដែលជាផ្នែកមួយនៃវប្បធម៌ និងជាតិសាសន៍របស់ចិន។

ពេលដែលអ្នកបានចម្រើនវ័យធំឡើង ក្នុងប្រពៃណីនេះ បានសម្រេចចិត្តទទួលជឿព្រះយេស៊ូវ គេបានចាត់ទុកអ្នកនោះ ជាមនុស្សដែលបានបោះបង់ចោល

ប្រពៃណី ហើយថែមទាំងបានក្បត់ជាតិសាសន៍ខ្លួនផងដែរ។ ពួកគេនាំមកនូវក្ដីអាម៉ាស់ដល់ក្រុមគ្រួសារ និងសហគមន៍ ដោយដើរតាមសាសនាបរទេស ហើយស្មោះស្ម័គ្រចំពោះព្រះរបស់បរទេស។

នៅក្នុងការចូលរួមពិធីសំខាន់ៗ ដូចជាពិធីមង្គលការ និងបុណ្យសព ឪពុកម្ដាយរបស់ពួកគេនឹង "បាក់មុខ" ហើយនឹងត្រូវអ្នកដទៃដៀលថា ចិញ្ចឹមកូនមិនបានល្អ។

ពួកគេក៏នាំមកនូវភាពអាប់ឱនដល់ឪពុកម្ដាយផងដែរ ព្រោះពួកគេនឹងមិនអាចធ្វើពិធីសាសនា ឲ្យឪពុកម្ដាយខ្លួន បន្ទាប់ពីឪពុកម្ដាយខ្លួនស្លាប់ទៅ ហើយក៏មិនអាចធ្វើការទំនុកបម្រុងឪពុកម្ដាយខ្លួនឲ្យបានត្រឹមត្រូវ នៅក្នុងស្ថានមនុស្សស្លាប់។

សម្រាប់ឪពុករបស់ខ្ញុំ រឿងនេះសំខាន់ចំពោះគាត់ជាពិសេស ព្រោះគាត់ជាកូនច្បងក្នុងគ្រួសារ និងជាសមាជិកសំខាន់ របស់សមាគមន៍ត្រកូលហាក់កា ដែលជាអង្គការផ្លូវការមួយ ដែលអភិរក្ស និងប្រកាន់ខ្ជាប់ នូវប្រពៃណីរបស់ជនជាតិចិន និងអំបូហាក់កា។

ឪពុកខ្ញុំគិតថា គាត់នឹងមានភាពអាម៉ាស់ ដោយសារខ្ញុំក្លាយជាគ្រីស្ទបរិស័ទ។ ម្ដាយខ្ញុំក៏បាននិយាយផងដែរថា ឪពុកខ្ញុំគិតថា គាត់បានធ្វើជាគំរូអាក្រក់ ដែលមិនបានចិញ្ចឹមកូនឲ្យកាន់តាមប្រពៃណីរបស់យើង ឲ្យបានត្រឹមត្រូវ។

ប៉ុន្តែ រឿងទាំងនេះមិនសំខាន់ចំពោះខ្ញុំទៀតឡើយ ពេលដែលខ្ញុំបានសម្រេចចិត្ត ដើរតាមព្រះយេស៊ូវ។ នៅពេលនោះ ខ្ញុំគ្រាន់តែបារម្ភថា តើជំនឿលើព្រះយេស៊ូវ ជាជំនឿដ៏ត្រឹមត្រូវមែនឬ? ខ្ញុំក៏បានសួរសំណួរដូចជា "តើខ្ញុំជានរណា? តើខ្ញុំរស់នៅ ក្នុងពិភពលោកនេះ ដើម្បីអ្វី? ហេតុអ្វីលោកិយនេះ មានភាពរញ៉េរញ៉ៃយ៉ាងនេះ ហើយតើមានដំណោះស្រាយទេ? តើបន្ទាប់ពីខ្ញុំស្លាប់ទៅ វិញ្ញាណខ្ញុំនឹងទៅកន្លែងណាទៀត?" កាលនោះ ខ្ញុំគិតថា ជំនឿរបស់គ្រីស្ទានហាក់ដូចជា

មានចម្លើយសម្រាប់សំណួរទាំងអស់នេះ។

រឿងនេះបានចាប់ផ្តើម នៅពេលដែលមិត្តភក្តិរបស់ខ្ញុំម្នាក់ដែលជាគ្រីស្ទបរិស័ទ ឈ្មោះ វេរ៉ូនីកា(Veronica) បានផ្សាយដំណឹងល្អប្រាប់ខ្ញុំ។ នាងបានចែកចាយ អំពីអ្វីដែលនាងបានរៀន ក្នុងព្រះគម្ពីរ នាងបានអញ្ជើញខ្ញុំ ឲ្យចូលរួមកម្មវិធីផ្សាយដំណឹងល្អ ហើយបង្ហាញខគម្ពីរ ដែលមានដូចជា យ៉ូហាន ៣:១៦ “ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ”។



*ឪពុកខ្ញុំគិតថា គាត់នឹងមានភាពអាម៉ាស់ ដោយសារខ្ញុំក្លាយជាគ្រីស្ទបរិស័ទ។*

ពីដំបូង ខ្ញុំមិនជឿអ្វីដែលនាងនិយាយទេ។ តើអ្វីដែលនាងនិយាយ ជាការពិតមែនឬ? គ្រីស្ទបរិស័ទដែលខ្ញុំស្គាល់ ក៏មិនឃើញមានជីវិតដែលល្អជាងខ្ញុំទេ ព្រោះពួកគេក៏នៅតែមានការពិបាក នៅក្នុងជីវិត។ ដូចនេះ តើខ្ញុំក្លាយជាគ្រីស្ទបរិស័ទ ដើម្បីអ្វី?

តើចំណែកឯព្រះយេស៊ូវវិញ តើទ្រង់មិនមែនជាបុរស ដែលមានសក់ពណ៌ត្នោត ហើយភ្នែកពណ៌ខៀវទេឬ?

ខ្ញុំបានសួរសំណួរជាច្រើនអំពីជីវិត ប៉ុន្តែ កាលនោះខ្ញុំកំពុងតែមានជីវិតល្អគួរសម។ ខ្ញុំមានគ្រួសារជាទីស្រឡាញ់ ខ្ញុំជាមនុស្សមានប្រជាប្រិយភាព ក្នុងចំណោមមិត្តភក្តិ ហើយខ្ញុំក៏បានទទួលលទ្ធផលល្អ ក្នុងផ្នែកកីឡា និងការរៀនសូត្រ។ ខ្ញុំមិនមានអារម្មណ៍ថា ខ្ញុំត្រូវការព្រះនោះទេ។ ចម្លើយដែលខ្ញុំរកឃើញ ក្នុងជំនឿគ្រីស្ទបរិស័ទ ហាក់ដូចជាសមហេតុផល តែខ្ញុំមិនគិតថា ខ្ញុំចាំបាច់ត្រូវធ្វើការសម្រេចចិត្តផ្ទាល់ខ្លួន ដើម្បីដើរតាមព្រះយេស៊ូវនោះឡើយ។

ប៉ុន្តែ នៅពេលល្ងាចមួយនោះ ពេលដែលខ្ញុំកំពុងតែគេងនៅលើគ្រែ ខ្ញុំមានអារម្មណ៍ថា ចិត្តរបស់ខ្ញុំកំពុងតែមានចន្លោះប្រហោង។ ដូចនេះ ខ្ញុំក៏បានអធិស្ឋានថា “ព្រះអង្គអើយ បើសិនព្រះអង្គពិតជាព្រះមែន តើព្រះអង្គអាចបង្ហាញទូលបង្គំឲ្យស្គាល់សេចក្តីពិតបានទេ?”

មិនយូរប៉ុន្មាន នៅពេលរសៀលថ្ងៃសៅរ៍ ពេលដែលខ្ញុំកំពុងតែដើរទៅរកតូបលក់ការ៉េម មានមនុស្សម្នាក់បានមកជួបខ្ញុំ។ គាត់ក៏បានសុំឲ្យខ្ញុំចំណាយពេលស្តាប់ដំណឹងល្អ។ ដើម្បីជាការគួរសម ខ្ញុំក៏បានយល់ព្រមអង្គុយស្តាប់គាត់ ។ នៅពេលនោះ ខ្ញុំបានឮខគម្ពីរដដែលៗ ដែលខ្ញុំធ្លាប់បានស្តាប់ជាច្រើនដងមកហើយ បានជាខ្ញុំថែមទាំងអាចសូត្រខគម្ពីរនោះទៀតផង។ ប៉ុន្តែ នៅថ្ងៃនោះ មានអ្វីម្យ៉ាងបានកើតឡើង។ ពេលដែលស្ត្រីនោះចែកចាយបទគម្ពីរ យ៉ូហាន ៣:១៦ ដល់ខ្ញុំ ខគម្ពីរនោះបានចាក់ដោតចិត្តខ្ញុំយ៉ាងខ្លាំង។



*សេចក្តីពិត ក្នុងបទគម្ពីរ យ៉ូហាន ៣:១៦ បានជ្រួតជ្រាបពីខួរក្បាលខ្ញុំ ចូលទៅដល់ដួងចិត្តខ្ញុំ។*

ខ្ញុំមានការប៉ះពាល់ចិត្ត មិនមែនដោយសារអ្វីដែលគាត់និយាយ ឬដោយសាររបៀបដែលគាត់និយាយនោះទេ។ នៅពេលនោះ ខ្ញុំជឿថា ព្រះវិញ្ញាណបរិសុទ្ធបានប៉ះពាល់ចិត្តខ្ញុំ ហើយសេចក្តីពិត ក្នុងបទគម្ពីរ យ៉ូហាន ៣:១៦ បានជ្រួតជ្រាបពីខួរក្បាលខ្ញុំ ចូលទៅដល់ដួងចិត្តខ្ញុំ។ ភ្លាមៗនោះ ខ្ញុំក៏បានដឹងច្បាស់ថា ខគម្ពីរនេះមានន័យដូចម្តេចចំពោះខ្ញុំ។

ខ្ញុំក៏បានដឹងថា ពាក្យ “មនុស្សលោក” ដែលព្រះទ្រង់បាន “ស្រឡាញ់ ដល់ម្ល៉េះ” គឺរាប់បញ្ចូលទាំងខ្ញុំផងដែរ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមានបន្ទុកនៃអំពើបាបដ៏ធ្ងន់ ហើយក៏បានទទួលស្គាល់ថា ខ្ញុំជាមនុស្សមានបាបធ្ងន់ប៉ុណ្ណា ហើយខ្ញុំត្រូវការព្រះយេស៊ូវខ្លាំងប៉ុណ្ណា។ ទីបំផុត ខ្ញុំក៏បានយល់ អំពីមូលហេតុដែលទ្រង់បាន

សុគត នៅលើឈើឆ្កាង ជំនួសខ្ញុំ ហើយខ្ញុំក៏អរព្រះគុណព្រះអង្គខ្លាំងណាស់ ដែលបានស្រឡាញ់ខ្ញុំ។ ដោយសារព្រះទ្រង់ស្រឡាញ់ខ្ញុំ ដ៏ម្ល៉េះ បានជាព្រះអង្គប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ឲ្យមកសុគតជំនួសខ្ញុំ ហើយបើខ្ញុំជឿព្រះអង្គ ខ្ញុំនឹងមិនវិនាសឡើយ តែមានជីវិតអស់កល្បជានិច្ច។

ពេលដែលសេចក្តីពិតនេះបានប៉ះពាល់ចិត្តខ្ញុំ ខ្ញុំក៏បានយំឥតឈប់។ វាជាលើកទីមួយហើយ ដែលខ្ញុំបានដឹងថា ខ្ញុំជាមនុស្សមានបាប។ ទន្ទឹមនឹងនោះ ខ្ញុំក៏អរព្រះគុណព្រះអង្គ សម្រាប់ការប្រទានការអត់ទោសបាប។ នៅថ្ងៃនោះ ខ្ញុំក៏បានសារភាពអំពើបាបរបស់ខ្ញុំ ដល់ព្រះយេស៊ូវ ហើយក៏បានទទួលព្រះអង្គ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះផ្ទាល់ខ្លួន។

ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីខ្ញុំមានក្តីអំណរដ៏ពោរពេញហើយ ខ្ញុំក៏បានចាប់ផ្តើមមានការថប់បារម្ភ។ ខ្ញុំក៏បានគិតដល់ផលវិបាក ដែលនឹងកើតឡើងពីការសម្រេចចិត្តរបស់ខ្ញុំ ហើយមិនយូរប៉ុន្មាន ខ្ញុំក៏បានដឹងថា ឪពុកម្តាយរបស់ខ្ញុំមានអារម្មណ៍ និងមានប្រតិកម្មយ៉ាងដូចម្តេច ចំពោះការសម្រេចចិត្តនេះ។ ខ្ញុំសួរខ្លួនឯងថា *តើខ្ញុំបានធ្វើអ្វីខុស? តើឪពុកម្តាយខ្ញុំនឹងនិយាយដូចម្តេច ពេលពួកគាត់ដឹងថា ខ្ញុំក្លាយជាគ្រីស្ទាន?*

ប៉ុន្តែ ស្ត្រីនោះបានលើកទឹកចិត្តខ្ញុំថា ក្នុងគ្រួសាររបស់ខ្ញុំ ខ្ញុំជាមនុស្សទីមួយ ដែលក្លាយជាគ្រីស្ទបរិស័ទ ហើយរឿងនេះជាព្រឹត្តិការណ៍ខាងវិញ្ញាណដ៏សំខាន់ក្នុងគ្រួសារខ្ញុំ។ គាត់ក៏បានរំឭកខ្ញុំ អំពីរឿងរបស់សាវ័កប៉ុល និងលោកស៊ីឡាស ដែលព្រះទ្រង់បានដោះខ្នោះច្រវ៉ាក់ចេញពីពួកគេ នៅក្នុងគុក ដោយការអស្ចារ្យ ហើយពួកគេក៏បានទៅផ្សាយព្រះបន្ទូលដល់អ្នកយាមគុក(កិច្ចការ ១៦:៣០-៣១)។ ពេលដែលអ្នកយាមគុកសួរពួកគេថា “តើគាត់ត្រូវធ្វើដូចម្តេច ដើម្បីឲ្យបានសង្គ្រោះ?” សាវ័កប៉ុលក៏បានប្រាប់គាត់ថា “ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងពួកគ្រួសារលោកផង”។

ជាការពិតណាស់ សាវ័កប៉ុល និងលោកស៊ីឡាស មិនបាននិយាយថា គ្រួសាររបស់អ្នកយាមគុក នឹងបានសង្គ្រោះ ដោយសារគាត់បានទទួលជឿព្រះនោះទេ។ ពួកគេម្នាក់ៗត្រូវតែទទួលសេចក្តីសង្គ្រោះ ដោយការឆ្លើយតបផ្ទាល់ៗខ្លួន ចំពោះព្រះ ហើយគេមិនអាចផ្ទេរសេចក្តីសង្គ្រោះ ពីម្នាក់ទៅម្នាក់បានឡើយ។ ទោះជាយ៉ាងណាក៏ដោយ ដំណឹងល្អអាចចាក់ឫស នៅក្នុងជីវិតគ្រួសារណាមួយ តាមរយៈមនុស្សទីមួយក្នុងគ្រួសារ ដែលងាកបែរមករកព្រះគ្រីស្ទ ដោយបើកចំហរទ្វារឲ្យក្រុមគ្រួសារទាំងមូលបានស្តាប់ និងមើលឃើញដំណឹងល្អ ដែលផ្សាយចេញតាមរយៈការប្រព្រឹត្តរបស់គាត់។

បទគម្ពីរកិច្ចការ ១៦:៣២ បានថែងថា បន្ទាប់ពីអ្នកយាមគុកបានទទួលជឿព្រះយេស៊ូវ លោកប៉ុល និងលោកស៊ីឡាស បានផ្សាយព្រះបន្ទូលព្រះអម្ចាស់ ដល់គាត់ និងក្រុមគ្រួសារគាត់ទាំងមូល។

ខគម្ពីរនេះបាននាំឲ្យខ្ញុំសង្ឃឹមថា ថ្ងៃណាមួយ ឪពុកម្តាយ និងបងប្អូនបង្កើតរបស់ខ្ញុំ នឹងបានស្គាល់ព្រះផងដែរ។ ខ្ញុំមានឱកាសធ្វើជាមនុស្សទីមួយ ដែលនាំព្រះរាជសារ និងធ្វើបន្ទាល់ដល់គ្រួសារខ្ញុំ។ ប៉ុន្តែ ជាដំបូង ខ្ញុំត្រូវប្រឈមមុខដាក់ការប្រឆាំងរបស់ពួកគេ។



*ទី២*

# ការជម្លះបញ្ហាប្រឈម

*បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្តាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ។-លូកា ១៤:២៦*

ក្នុង **រយៈពេលពីរបីខែដំបូង** ខ្ញុំមិនបាននិយាយអ្វីទាំងអស់ អំពីជំនឿដែលខ្ញុំទើបតែមាន។ ខ្ញុំមិនហ៊ាននិយាយប្រាប់ឪពុកម្តាយខ្ញុំឡើយ ព្រោះខ្ញុំខ្លាចមានរឿងកើតឡើង។ មនុស្សម្នាក់គត់ ដែលខ្ញុំនិយាយប្រាប់ គឺបងប្អូនភ្លោះរបស់ខ្ញុំដែលខ្ញុំអាចទុកចិត្តថា គាត់នឹងរក្សារឿងអាថ៌កំបាំងរបស់ខ្ញុំ។ នាងបានមើលមកខ្ញុំដោយការភ្ញាក់ផ្អើល ហើយក៏បានលើកម្រាមដៃមកធ្វើជាការសញ្ញាដាស់តឿនដល់ខ្ញុំថា “ឯងនឹងមានរឿងមិនខាន ពេលដែលម៉ាក់ និងប៉ាដឹងអំពីរឿងនេះ!”

ខ្ញុំក៏មិនហ៊ានទៅព្រះវិហារដែរ ប៉ុន្តែ បានទទួលការទ្រទ្រង់ខាងវិញ្ញាណ តាមរយៈការអធិស្ឋានជាប់ជានិច្ច ការអានព្រះគម្ពីរ និងការជួបជុំជាទៀងទាត់ ជាមួយមិត្តភក្តិ ដែលជាគ្រីស្ទបរិស័ទ ដែលបានបង្រៀនខ្ញុំអំពីព្រះ នៅក្រោយម៉ោងរៀន។ រៀងរាល់ពេលព្រឹក ខ្ញុំបានចំណាយពេលអធិស្ឋានទៅរកព្រះ និងអានព្រះគម្ពីរ ប៉ុន្តែ ខ្ញុំបានលាក់ព្រះគម្ពីរនោះ បន្ទាប់ពីអានហើយ ដើម្បីកុំឲ្យពួកគាត់ដឹង។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនអាចលាក់រឿងនេះបានយូរទេ។

ថ្ងៃមួយ ខ្ញុំបានភ្លេចព្រះគម្ពីរនៅលើតុ។ ប៉ាខ្ញុំក៏បានឃើញ ហើយដឹងថា ព្រះគម្ពីរប៊ីបរបស់ខ្ញុំជាសៀវភៅអ្វី។ ក្នុងនាមគាត់ជាឪពុកដែលកាន់ប្រពៃណីចិន គាត់មិនបានប្រឈមមុខដាក់ខ្ញុំដោយផ្ទាល់ទេ តែគាត់បានប្រាប់ម៉ាក់ឲ្យសួរនាំខ្ញុំអំពីរឿងព្រះគម្ពីរនោះ។ មិនយូរប៉ុន្មាន គាត់ក៏បានអង្គុយចុះ ហើយក៏បានសួរត្រង់ៗតែម្តងថា “ហេតុអ្វីបានជាកូនអានព្រះគម្ពីរប៊ីប?”

ពេលនោះ ខ្ញុំមិនដឹងថាត្រូវនិយាយដូចម្តេចទេ ក្រៅពីសារភាពថា ខ្ញុំបានក្លាយជាគ្រីស្ទានហើយ។ ម៉ាក់អស់ពាក្យនិយាយ ហើយក៏បានគ្រវីក្បាល ដោយការស្រងាកចិត្ត។ ក្នុងអំឡុងពេលពីរបីថ្ងៃបន្ទាប់ ខ្ញុំមិនឃើញមានរឿងអ្វីទៀតកើតឡើងទេ។ ម៉ាក់ប៉ាខ្ញុំមិនបាននិយាយអ្វីទៀត អំពីបញ្ហានេះ តែខ្ញុំមានអារម្មណ៍តានតឹងយ៉ាងខ្លាំង។ ខ្ញុំដឹងថា ខ្ញុំនឹងមានរឿងច្រើនជាងនេះទៀត។

ប៉ុន្មានថ្ងៃក្រោយមក ប៉ាក៏បានហុចសំបុត្រមួយច្បាប់មកខ្ញុំ ដោយផ្ទាល់ដៃ ហើយក៏បានចេញទៅធ្វើការ ដោយមិននិយាយអ្វីមួយម៉ាត់។ ក្នុងនោះ គាត់បានសរសេរ អំពីការខកចិត្ត និងការពិបាកចិត្ត ដែលគាត់មាន ដោយសារខ្ញុំក្លាយជាគ្រីស្ទាន។ គាត់ក៏បានសរសេរអំពីបរាជ័យរបស់គាត់ ក្នុងនាមជាឪពុក ដែលមិនបានគ្រប់គ្រងគ្រួសារឲ្យបានល្អ ហើយក៏បានប្រាប់ថា ខ្ញុំអាចនឹងមានរឿង ដោយសារទង្វើររបស់ខ្ញុំ។

គាត់ក៏បានចង្អុលបង្ហាញថា យើងមិនអាចមានព្រះពីរផ្សេងគ្នា នៅក្នុងផ្ទះតែមួយបានឡើយ។ ក្រុមគ្រួសារខ្ញុំបានសច្ចាថា នឹងស្មោះស្ម័គ្រចំពោះព្រះមួយក្រុម ដោយជឿថា ព្រះទាំងនោះ នឹងជួយឲ្យយើងមានភាពសុខសាន្ត ភាពសុខដុម និងសុវត្ថិភាព ដែលជាអ្វីដែលឪពុកម្តាយខ្ញុំចង់ឲ្យយើងមាន។ ប៉ុន្តែ ពេលនោះ ខ្ញុំបានងាកបែរខ្នងដាក់ជំនឿរបស់ក្រុមគ្រួសាររបស់ខ្ញុំ ហើយបានដើរតាមព្រះយេស៊ូវ ដូចនេះ ពួកគេគិតថា ខ្ញុំបានធ្វើឲ្យព្រះទាំងនោះខឹង ហើយធ្វើឲ្យក្រុមគ្រួសារយើងងាយរងគ្រោះ។

នៅពេលរសៀលដដែលនោះ ម៉ាក់បានឲ្យខ្ញុំអង្គុយចុះ ហើយក៏បានយករឿងសំបុត្រនោះមកនិយាយ។ ពេលនេះ ខ្ញុំអាចមើលដឹងថា គាត់ខឹងនឹងខ្ញុំហើយ។ គាត់ក៏បាននិយាយដោយសម្លេងឮៗជាងមុនថា "ប៉ាកូនគេមិនសូវបានគេងទេ។ គាត់កំពុងតែពិបាកចិត្ត។ គាត់មានអារម្មណ៍ថា គាត់បរាជ័យ។ កូនមើលអ្វីដែលកូនបានធ្វើចុះ! កូនមិនបានបំពេញករណីកិច្ចជាកូនទេ។ ប៉ាកម៉ាក់ខំចិញ្ចឹមអប់រំកូន តើកូនសងគុណប៉ាម៉ាក់វិញយ៉ាងដូចនេះឬ?"

ម៉ាក់ក៏បានចង្អុលបង្ហាញផងដែរថា ការសម្រេចចិត្តរបស់ខ្ញុំ មានន័យដូចម្តេចចំពោះក្រុមគ្រួសារយើង។ គាត់ថា "ចុះបើសិនជាបងប្អូនបង្កើតរបស់កូន ធ្វើមកលើកូនដូចនេះដែរ តើកូនមានអារម្មណ៍យ៉ាងណា? តើនរណានឹងធ្វើពិធីបុណ្យសពឲ្យប៉ាម៉ាក់? តើនរណានឹងដុតធូបឲ្យប៉ាម៉ាក់? តើសាច់ញាតិរបស់ប៉ាកូននឹងនិយាយថាម៉េចខ្លះ អំពីកូន? កូនបាននាំមកនូវក្តីអាម៉ាស់មកលើយើងទាំងអស់គ្នា!"

គាត់ក៏បាននិយាយ អំពីការព្រួយបារម្ភមួយចំនួន ដែលគាត់និងប៉ាខ្ញុំមានចំពោះខ្ញុំ។ គាត់សួរខ្ញុំថា តើខ្ញុំកំពុងតែត្រូវបានគេនាំឲ្យវង្វេងឬ? តើនរណានាំខ្ញុំឲ្យចូលសាសនាគេ ដោយនាំខ្ញុំឲ្យងាកចេញពីប្រពៃណីរបស់គ្រួសារ?

ខ្ញុំមិនបានព្យាយាមការពារខ្លួនឯង ឬប្រកែកជាមួយគាត់ឡើង តែគ្រាន់តែបានស្តាប់គាត់ ដោយមិននិយាយអ្វីទាំងអស់។ ម៉ាក់ប្រហែលជាកំពុងតែសង្ឃឹមថា គាត់អាចផ្លាស់ប្តូរគំនិតខ្ញុំ ប៉ុន្តែ ខ្ញុំនៅតែមិនឆ្លើយតប។ មួយសន្ទុះក្រោយមក គាត់ក៏ឈប់និយាយ។ ខ្ញុំវិលត្រឡប់ទៅបន្ទប់ខ្ញុំវិញ ដើម្បីគិតអំពីអ្វីដែលគាត់បាននិយាយ និងដើម្បីស្វែងរកជំនួយមកពីព្រះ។

ខ្ញុំអធិស្ឋានថា "ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំពិបាកចិត្តណាស់ពេលដែលរឿងនេះបានផលប៉ះពាល់មកលើគ្រួសារទូលបង្គំច្រើនយ៉ាងនេះ ប៉ុន្តែសូមព្រះអង្គជួយទូលបង្គំ ឲ្យនៅតែមានជំនឿរឹងមាំ។ ទូលបង្គំដឹងថា ព្រះអង្គពិតជាមានមែន ប៉ុន្តែ ទូលបង្គំត្រូវការកម្លាំង ដើម្បីស៊ូទ្រាំ"។

ខ្ញុំកំពុងតែប្រឈមមុខដាក់ស្ថានភាពដ៏ពិបាក។ ខ្ញុំមានអារម្មណ៍ថា ពួកគាត់

កំពុងតែឲ្យខ្ញុំធ្វើការសម្រេចចិត្តជ្រើសរើសរវាងព្រះ និងពួកគាត់ តែឪពុកម្ដាយខ្ញុំ និងព្រះយេស៊ូវសុទ្ធតែសំខាន់ចំពោះខ្ញុំ។ ប៉ាម៉ាក់ខ្ញុំចង់ឲ្យខ្ញុំបោះបង់ចោលព្រះ "របស់បរទេស" តែខ្ញុំដឹងថា ខ្ញុំមិនអាចធ្វើបានទេ។ ទន្ទឹមនឹងនោះ ខ្ញុំមិនឲ្យឪពុកម្ដាយខ្ញុំគិតថា ខ្ញុំកំពុងតែចាកចេញពីពួកគាត់នោះឡើយ។

ព្រះយេស៊ូវបានមានបន្ទូល អំពីបញ្ហាប្រឈមនេះ នៅក្នុងបទគម្ពីរ លូកា ១៤:២៦ ថា "បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្ដាយ ប្រពន្ធ កូន បងប្អូនប្រុសស្រី និងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ"។ ត្រង់ចំណុចនេះ ព្រះយេស៊ូវមិនបានមានបន្ទូលតាមន័យត្រង់ ឲ្យពួកសិស្សស្អប់ក្រុមគ្រួសាររបស់ខ្លួននោះឡើយ។ ព្រះអង្គកំពុងតែជំរុញពួកគេ ឲ្យគិតអំពីការលះបង់ ដើម្បីធ្វើជាសិស្សរបស់ព្រះអង្គ ហើយក៏បានសួរពួកគេថា តើពួកគេបានត្រៀមខ្លួន ដើម្បីទទួលព្រះអង្គជាម្ចាស់នៃជីវិតរបស់ពួកគេហើយឬនៅ។ បន្ទាប់ពីព្រះអង្គបានមានបន្ទូលនូវពាក្យទាំងនេះហើយ ភ្លាមៗនោះ ព្រះអង្គក៏បានមានបន្ទូលជាពាក្យប្រៀបប្រដូចមួយចំនួន អំពីអ្នកដែលមិនបានត្រៀមខ្លួនបញ្ចប់អ្វីដែលខ្លួនបានចាប់ផ្ដើម។ មានបុរសម្នាក់ ដែលមិនបានប៉ាន់ស្មានថា ខ្លួនមានប្រាក់គ្រប់គ្រាន់ ដើម្បីចាប់ផ្ដើមការសាងសង់ ហើយមានស្ដេចមួយអង្គ ដែលមិនបានគិតពិចារណាថា ខ្លួនមានទ័ពគ្រប់គ្រាន់ មុនពេលធ្វើសង្គ្រាម។

ត្រង់ចំណុចនេះ ព្រះយេស៊ូវកំពុងតែសួរថា តើអ្នកហ៊ានលះបង់ច្រើនប៉ុណ្ណា ដើម្បីដើរតាមខ្ញុំ? តើអ្នកបានត្រៀមខ្លួន ដើម្បីយកខ្ញុំជាទីមួយ ជាសំខាន់ជាងក្រុមគ្រួសាររបស់អ្នកឬទេ? តើអ្នកបានត្រៀមខ្លួន ដើម្បីលះបង់អ្វីៗទាំងអស់ ដែលអ្នកស្រឡាញ់ ដោយរាប់បញ្ចូលទាំងជីវិតរបស់អ្នកឬទេ?

កាលនោះ ខ្ញុំកំពុងតែជួបបញ្ហាប្រឈមមួយនេះឯង។ តើខ្ញុំហ៊ានលះបង់ច្រើនប៉ុណ្ណា ដើម្បីដើរតាមព្រះយេស៊ូវ? តើខ្ញុំស្ម័គ្រចិត្តទទួលព្រះអង្គជាម្ចាស់នៃជីវិតខ្ញុំ ដោយមិនខ្លាចឪពុកម្ដាយខ្ញុំមិនសប្បាយចិត្តឬ? តើខ្ញុំគួរតែធ្វើការផ្សះផ្សា និងថ្លឹងថ្លែងឲ្យស្មើគ្នា រវាងសេចក្ដីស្រឡាញ់ចំពោះព្រះយេស៊ូវ និងសេចក្ដីស្រឡាញ់ចំពោះឪពុកម្ដាយខ្ញុំ ដោយរបៀបណា?



*ទីបី*

# ការជឿទុកចិត្តចំពោះការធានា

*“ទ្រង់ក៏មានព្រះបន្ទូលពាក្យប្រៀបទៅគេថា តើមនុស្សខ្វាក់អាចនឹងដឹកមនុស្សខ្វាក់បានឬទេ តើមិនធ្លាក់ទៅក្នុងរណ្តៅទាំង២នាក់ទេឬអី?” -លូកា ៦:៣៩*

**ខ្ញុំសង្ឃឹមថា** ខ្ញុំអាចរកឃើញវិធីឆ្លើយសំណួររបស់ឪពុកម្តាយខ្ញុំ ហើយត្រូវនិយាយអំពីអ្វីខ្លះប្រាប់ពួកគាត់។ ផ្ទុយទៅវិញ ខ្ញុំបានទទួលការដឹកនាំដ៏សាមញ្ញមួយមកពីព្រះ ឲ្យធ្វើជាស្មរបន្ទាល់របស់ព្រះអង្គ។

ការឆ្លើយតបនេះ បាននាំឲ្យខ្ញុំមានការកម្សាន្តចិត្តខ្លាំងណាស់។ ព្រះអង្គហាក់ដូចជាកំពុងតែប្រាប់ខ្ញុំថា ការដែលខ្ញុំបានសម្រេចចិត្តដើរតាមព្រះអង្គ គឺជាទង្វើរដ៏ត្រឹមត្រូវ ហើយបេសកកម្មរបស់ខ្ញុំ នៅពេលនេះ គឺត្រូវចែកចាយ អំពីការរុករកឃើញរបស់ខ្ញុំ ដល់ក្រុមគ្រួសារខ្ញុំ។ ពេលដែលខ្ញុំកំពុងសម្រេចចិត្តជ្រើសរើសយកព្រះ ឬគ្រួសាររបស់ខ្ញុំ ព្រះអង្គក៏បានត្រាស់ហៅខ្ញុំ ឲ្យចែកចាយ អំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ ដល់ពួកគេ។

មានមនុស្សម្នាក់បានលើកទឹកចិត្តខ្ញុំ ដោយនិយាយប្រៀបប្រដូច អំពីបេសកកម្មរបស់ខ្ញុំថា : ឧបមាថា អ្នក និងក្រុមគ្រួសាររបស់អ្នកកំពុងតែរស់នៅ ក្នុងប្រអប់បិទជិតមួយ។ ពេលនោះ ពិភពលោករបស់អ្នក គឺនៅក្នុងប្រអប់នោះហើយ។

អ្នកអាចមើលឃើញតែអ្វីៗ ដែលមានក្នុងប្រអប់នោះប៉ុណ្ណោះ។ បើនរណាម្នាក់ប្រាប់អ្នកថា ពិភពលោកដែលនៅក្រៅប្រអប់ធំជាង និងល្អជាង នោះអ្នកប្រហែលជាគិតថា គាត់កំពុងតែនិយាយរឿងដែលគួរឲ្យអស់សំណើចហើយ។ ទោះជាយ៉ាងណាក៏ដោយ ថ្ងៃមួយ អ្នករកឃើញកូនសោរមួយ ដែលអាចបើកទ្វារប្រអប់នោះ។ អ្នកបើកទ្វារនោះចេញមកក្រៅប្រអប់ ហើយក៏បានដឹងថា គាត់ពិតជានិយាយត្រូវមែន។ នៅក្រៅប្រអប់នោះ ពិតជាមានពិភពលោក ដែលធំជាង និងល្អជាងអ្វីៗដែលអ្នកឃើញក្នុងប្រអប់។

តើអ្នកនឹងធ្វើដូចម្ដេច? តើអ្នកនឹងបោះកូនសោរចោល ហើយបន្តនៅក្នុងប្រអប់ជាមួយគ្រួសារអ្នក ដោយសារអ្នកមិនចង់ធ្វើឲ្យមានភាពល្អក់កករ ក្នុងគ្រួសារឬ? ឬអ្នកនឹងបោះជំហានចេញពីប្រអប់នោះ ដើម្បីស្វែងយល់អំពីពិភពនៅខាងក្រៅ រួចត្រឡប់មកក្រុមគ្រួសារអ្នក ដើម្បីប្រាប់ពួកគេអំពីអ្វីដែលអ្នកបានដឹងឬ?

បទគម្ពីរ លូកា ៦:៣៩ បាននិយាយសង្កត់ធ្ងន់ អំពីសារៈសំខាន់នៃការទទួលស្គាល់ និងយល់អំពីសេចក្ដីពិត មុននឹងយើងព្យាយាមចែកចាយ សេចក្ដីពិតនោះដល់អ្នកដទៃ។ គឺដូចដែលព្រះយេស៊ូវបានមានបន្ទូលថា “តើមនុស្សខ្វាក់អាចនឹងដឹកមនុស្សខ្វាក់បានឬទេ តើមិនធ្លាក់ទៅក្នុងរណ្ដៅទាំង២នាក់ទេឬអី?” (លូកា ៦:៣៩)។ យើងមិនអាចដឹកនាំអ្នកដទៃ ឲ្យដើរតាមផ្លូវត្រូវបានឡើយ បើសិនជាយើងមិនដឹងច្បាស់ថា ផ្លូវដែលយើងកំពុងតែដើរនោះ ជាផ្លូវត្រូវ។

ខគម្ពីរនេះបានលើកទឹកចិត្តខ្ញុំខ្លាំងណាស់។ ឥឡូវនេះ ខ្ញុំបានរកឃើញសេចក្ដីពិតហើយ មានតែព្រះយេស៊ូវទេ ដែលអាចសង្គ្រោះយើង ហើយខ្ញុំអាចនាំគ្រួសារខ្ញុំ ទៅរកសេចក្ដីពិតដ៏អស្ចារ្យនេះ។ ហើយវិធីល្អបំផុត ដើម្បីនាំពួកគេឲ្យស្គាល់សេចក្ដីពិតនេះ គឺត្រូវស្រឡាញ់ និងគោរពឪពុកម្ដាយខ្ញុំ។ តាមរយៈពាក្យសម្ដី និងការប្រព្រឹត្តរបស់ខ្ញុំ ខ្ញុំអាចបង្ហាញពួកគាត់ឲ្យស្គាល់ព្រះគ្រីស្ទ ដែលជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះនៃពិភពលោក។ បេសកកម្មថ្មីមួយនេះបានជួយឲ្យខ្ញុំយល់កាន់

តែច្បាស់ អំពីសេចក្តីជំនឿរបស់ខ្ញុំ។ មុនពេលខ្ញុំចែកចាយ អំពីអ្វីដែលខ្ញុំទើបតែរកឃើញនោះ ខ្ញុំដឹងថា ខ្ញុំត្រូវយល់ច្បាស់ អំពីសេចក្តីជំនឿរបស់ខ្ញុំ។

ក្នុងដំណាក់កាលនោះ ខ្ញុំត្រូវតែមានលទ្ធភាពឆ្លើយសំណួរមូលដ្ឋានមួយចំនួន ដូចជា : តើព្រះយេស៊ូវជាព្រះមែនឬ តើជំនឿលើព្រះគ្រីស្ទគ្រាន់តែជាសាសនាមួយទៀតឬ? តើព្រះអង្គពិតជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះនៃពិភពលោកមែនឬ?

ហេតុអ្វីខ្ញុំគួរតែថ្វាយបង្គំព្រះអង្គ? តើខ្ញុំអាចជឿទុកចិត្ត ចំពោះការអ្វីដែលព្រះគម្ពីរបានចែង អំពីព្រះអង្គ និងអំពីកិច្ចការដែលព្រះអង្គបានធ្វើឬទេ?



*ពេលដែលខ្ញុំកំពុងសម្រេចចិត្តជ្រើសរើស យកព្រះ ឬគ្រួសាររបស់ខ្ញុំ ព្រះអង្គក៏បានត្រាស់ហៅខ្ញុំ ឲ្យចែកចាយ អំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវដល់ពួកគេ។*



*ទី៤*

# ការស្វែងយល់អំពីជំនឿឲ្យបានច្បាស់

*ហើយគ្មានសេចក្ដីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ។ កិច្ចការ ៤:១២*

**ដើម្បីឆ្លើយសំណួរទាំងនេះ** ខ្ញុំក៏បានគិតឡើងវិញ អំពីពេលដែលខ្ញុំសម្រេចចិត្តដើរតាមព្រះយេស៊ូវគ្រីស្ទ តាំងពីពេលដំបូង ហើយមើលព្រះបន្ទូលក្នុងព្រះគម្ពីរប៊ីប។

**តើព្រះយេស៊ូវពិតជាព្រះមែនឬ?** ដោយសារខ្ញុំចូលចិត្តអានសៀវភៅ នោះខ្ញុំក៏បានរកឃើញកំណត់ត្រាប្រវត្តិសាស្ត្រជាច្រើន ដែលបានបង្ហាញថា ព្រះយេស៊ូវពិតជាបានរស់នៅ លើផែនដីនេះ កាលពីជាង២ពាន់ឆ្នាំមុន ហើយទ្រង់ត្រូវគេឆ្កាងរហូតដល់អស់ព្រះជន្ម។ ប៉ុន្តែ ក្នុងចំណោមនោះ មានកំណត់ត្រាជាច្រើន ដែលមិនសូវនិយាយ អំពីការអះអាងរបស់ព្រះយេស៊ូវថា ព្រះអង្គជាព្រះរាជបុត្រានៃព្រះ ហើយយើងអាចផ្សះផ្សាឲ្យជានឹងព្រះ ដោយទទួលជឿព្រះអង្គ ហើយព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ បន្ទាប់ពីព្រះអង្គសុគតបានបីថ្ងៃ។ ខ្ញុំត្រូវតែពិចារណា អំពីការអះអាងរបស់ព្រះអង្គ ហើយសម្រេចចិត្តជឿថា អ្វីដែលព្រះ

អង្គមានបន្ទូលនោះ ជាការពិតឬអត់។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលលោកស៊ីអេស លូអ៊ីស(C. S. Lewis) ដែលជាអ្នកនិពន្ធគ្រីស្ទបរិស័ទ បាននិយាយ បានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលណាស់។ គាត់បានសង្កេតឃើញថា ដោយសារព្រះយេស៊ូវបានធ្វើការអះអាងដូចនេះ បើព្រះអង្គមិនមែនជាព្រះរាជបុត្រានៃព្រះទេ នោះព្រះអង្គជាមនុស្សកុហក់ ឬជាមនុស្សឆ្កួតហើយ។ ពេលដែលខ្ញុំបានអានព្រះគម្ពីរប៊ីប និងសៀវភៅដទៃទៀត ខ្ញុំក៏បានធ្វើការសន្និដ្ឋានថា អ្វីដែលព្រះយេស៊ូវមានបន្ទូល គឺជាការពិតមែន។ ទ្រង់ជាព្រះរាជបុត្រានៃព្រះ ទ្រង់យាងចុះមកផែនដី ដើម្បីសុគតជំនួសយើង ព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ ហើយកាលណាយើងទទួលជឿព្រះអង្គ យើងនឹងមានជីវិតអស់កល្បជានិច្ច។

ខ្ញុំក៏មានការប៉ះពាល់ចិត្ត ពេលដែលបានដឹងថា ព្រះទ្រង់ស្រឡាញ់ខ្ញុំខ្លាំងយ៉ាងនេះ។ ព្រះគម្ពីរបានចែងថា ព្រះអង្គបានបង្កើតពិភពលោកមក ដោយសារព្រះអង្គជាសេចក្តីស្រឡាញ់ ហើយព្រះអង្គសព្វព្រះទ័យនឹងចែករំលែកសេចក្តីស្រឡាញ់របស់ព្រះអង្គ។ ព្រះអង្គបានបង្កើតមនុស្សជាតិ ដើម្បីមានទំនាក់ទំនងជាមួយពួកគេ ប៉ុន្តែយើងបានបះបោរប្រឆាំងនឹងព្រះអង្គ។ ការមិនស្តាប់បង្គាប់របស់យើងគឺជាអំពើបាបដែលបានបណ្តាលឲ្យយើងដាច់ចេញពីព្រះ។

ទោសនៃអំពើបាប គឺជាសេចក្តីស្លាប់ ប៉ុន្តែព្រះទ្រង់បានចាត់ព្រះរាជបុត្រាព្រះអង្គ ឲ្យមកសុគតជំនួសយើង ដើម្បីឲ្យយើងអាចទទួលការអត់ទោស ហើយវិលត្រឡប់មករកការប្រកបស្និទ្ធស្នាលជាមួយព្រះអង្គវិញ។ បទគម្ពីរកិច្ចការ ៤:១២ បានចែងថា “គ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃគ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ”។

**តើព្រះគម្ពីរប៊ីបមានលក្ខណៈដែលគួរឲ្យជឿឬទេ?** ខ្ញុំបានបន្តមើលព្រះគម្ពីរប៊ីបដើម្បីស្វែងយល់អំពីលក្ខណៈរបស់ព្រះយេស៊ូវ មូលហេតុដែលព្រះអង្គយាងចុះមក

ផែនដី ការអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង និងមូលហេតុដែលយើងត្រូវតែជឿព្រះអង្គ។ ពេលនោះខ្ញុំក៏បានដឹងថា ជំនឿលើព្រះគ្រីស្ទពឹងផ្អែកទាំងស្រុង ទៅលើការអ្វីដែលមានចែងក្នុងព្រះគម្ពីរប៊ីប ប៉ុន្តែ តើខ្ញុំអាចទុកចិត្តព្រះគម្ពីរឬទេ?

ដូចនេះ ខ្ញុំក៏បានស្វែងយល់ប្រវត្តិព្រះគម្ពីរប៊ីប ហើយបានដឹងថា ព្រះគម្ពីរប៊ីបមាន៦៦កណ្ឌ ដែលត្រូវបាននិពន្ធដោយអ្នកនិពន្ធ៤០នាក់ ក្នុងចន្លោះរយៈពេលជាង ១៥០០ឆ្នាំ។ ធម្មតា សៀវភៅដែលនិពន្ធ ដោយអ្នកនិពន្ធច្រើននាក់ ក្នុងចន្លោះរយៈពេលដ៏វែងយ៉ាងនេះ អាចមានទស្សនៈដែលប៉ះទង្គិចគ្នា និងការពិពណ៌នាដែលប្រឆាំងគ្នាហើយ។ ប៉ុន្តែ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ ពេលដែលបានដឹងថា កណ្ឌទាំង៦៦នៃព្រះគម្ពីរប៊ីប មានភាពស៊ីសង្វាក់គ្នា ហើយខ្លឹមសារនៃកណ្ឌទាំងអស់ក៏មានការរួបរួមគ្នាតែមួយផងដែរ។ កណ្ឌគម្ពីរទាំងនោះនិយាយអំពីព្រះតែមួយ អំពីសេចក្តីស្រឡាញ់ដែលព្រះអង្គមានចំពោះមនុស្សជាតិទាំងអស់ និងអំពីសេចក្តីបរិសុទ្ធឥតខ្ចោះរបស់ព្រះអង្គ។ ហើយកណ្ឌគម្ពីរនីមួយៗសុទ្ធតែចង្អុលបង្ហាញមនុស្ស ឲ្យងាកទៅរកព្រះយេស៊ូវ ដែលមានតែព្រះអង្គទេដែលអាចជួយសង្គ្រោះយើង និងជួយយើងឲ្យមានទំនាក់ទំនងជាមួយព្រះ។

ខ្ញុំក៏បានដឹងផងដែរថា ព្រះគម្ពីរមានមូលដ្ឋានគ្រឹះប្រវត្តិសាស្ត្រ ដែលក្នុងនោះរឿងជាច្រើនក្នុងព្រះគម្ពីរដែលនិយាយអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រធំៗ មានភស្តុតាង នៅក្នុងសិលាចារិក និងវត្ថុបុរាណ។

ពេលដែលខ្ញុំគិតអំពីចំណុចសំខាន់ៗទាំងអស់នេះ ខ្ញុំអាចដឹងថា ព្រះគម្ពីរត្រូវបាននិពន្ធ ដោយមនុស្សប្រហែល៤០នាក់ ប៉ុន្តែ ព្រះទ្រង់ជាអ្នកបណ្តាលចិត្តពួកគេឲ្យនិពន្ធ។ គឺដូចដែលសាវ័កប៉ុលបានរំឭកលោកធីម៉ូថេ ដែលជាសិស្សរបស់គាត់ថា "គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត"(២ធីម៉ូថេ ៣:១៦)។

**ហេតុអ្វីបានជាខ្ញុំគួរតែជឿព្រះអង្គ?** ដូចនេះ ព្រះយេស៊ូវគឺជាព្រះពិតមែន ហើយយើងក៏អាចជឿព្រះគម្ពីរផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ហេតុអ្វីខ្ញុំគួរតែជឿព្រះអង្គ? ដោយសារខ្ញុំបានរៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅសាលា ខ្ញុំបានរកឃើញថា ខ្ញុំអាចយល់អំពីជំនឿរបស់គ្រីស្ទបរិស័ទកាន់តែច្បាស់ ដោយប្រៀបធៀបភាពពិតនៃព្រះគ្រីស្ទ ជាមួយនឹងទ្រឹស្តីនៃទំនាញផែនដី។ ខ្ញុំកំពុងតែស្ថិតនៅក្រោមឥទ្ធិពលនៃទំនាញផែនដី ទោះខ្ញុំមិនជឿថា ទំនាញផែនដីមានពិតមែនក៏ដោយ។ ទោះខ្ញុំខំធ្វើឲ្យខ្លួនខ្ញុំឡើងទៅលើយ៉ាងណាក៏ដោយ ក៏ទំនាញផែនដីនៅតែទាញខ្ញុំឲ្យចុះមកផែនដី។ ខ្ញុំអាចទទួលស្គាល់វា ហើយរស់នៅតាមច្បាប់របស់វា ឬធ្វើពុតជាជឿថា វាមិនពិតជាមានមែន ហើយទទួលផលវិបាកពីការមិនជឿនោះ។

យ៉ាងណាមិញ ខ្ញុំក៏បានឃើញសេចក្តីពិតនៃព្រះយេស៊ូវ មានឥទ្ធិពលមកលើខ្ញុំផងដែរ ទោះខ្ញុំជឿ ឬមិនជឿក៏ដោយ។ ដូចនេះ ខ្ញុំត្រូវតែជឿ។ រឿងនេះមិនមែនជាការសម្រេចចិត្តជ្រើសរើសសាសនា ឬអ្នកដឹកនាំ សម្រាប់ដើរតាមនោះទេ ព្រោះបើព្រះយេស៊ូវពិតជាផ្លូវតែមួយទៅរកសេចក្តីសង្គ្រោះ និងជីវិតអស់កល្បនោះខ្ញុំត្រូវតែជឿព្រះអង្គ។

បទគម្ពីរយ៉ូហាន ១:៣ បានចែងថា “គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ”។

រឿងអីដែលខ្ញុំមិនដើរតាមព្រះ ដែលជាប្រភពនៃជីវិតខ្ញុំ? រឿងអីដែលខ្ញុំបែរខ្នងដាក់ព្រះអាទិកររបស់ខ្ញុំ ដែលបានព្យាយាមផ្សះផ្សាទំនាក់ទំនងជាមួយខ្ញុំ និងក្រុមគ្រួសារខ្ញុំ?

ពេលដែលខ្ញុំរំឭកខ្លួនឯង អំពីពេលដែលខ្ញុំបានសម្រេចចិត្តដើរតាមព្រះ ខ្ញុំក៏បាននឹកចាំថា ខ្ញុំមិនបានសម្រេចចិត្តដើរតាមព្រះ ទាំងងងឹតងងល់នោះឡើយ។ ខ្ញុំ

បានយល់ខ្លឹមសារនៃដំណឹងល្អ ហើយក៏បានដឹងថា ខ្ញុំកំពុងតែជឿអ្វី ហើយហេតុអ្វីខ្ញុំជឿ។ ជាងនេះទៅទៀត ជំនឿរបស់ខ្ញុំក៏បាននាំឲ្យខ្ញុំមានការប្ដេជ្ញាចិត្ត។ ខ្ញុំដឹងថា មានតែព្រះយេស៊ូវទេ ដែលអាចជួយសង្គ្រោះដូចនេះ ខ្ញុំបានសម្រេចចិត្តថ្វាយខ្លួនដល់ព្រះអង្គ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់ខ្ញុំ ដោយថ្វាយជីវិត និងមានការស្ម័គ្រស្មោះចំពោះព្រះអង្គ។ នេះជាការសម្រេចចិត្ត អស់ពីចិត្ត និងគំនិត។ ចម្លើយដែលមានក្នុងព្រះគម្ពីរមិនគ្រាន់តែបានធ្វើឲ្យជំនឿខ្ញុំ កាន់តែរឹងមាំប៉ុណ្ណោះទេ ប៉ុន្តែ ក៏បានជួយឲ្យខ្ញុំគិត អំពីអត្ថន័យនៃការរស់នៅជាគ្រីស្ទបរិស័ទផងដែរ។ ខ្ញុំចង់បង្ហាញប៉ាម៉ាក់ខ្ញុំថា ការជឿព្រះយេស៊ូវ គឺមិនមានន័យថា ខ្ញុំបានបែរខ្នងដាក់កេរដំណែល និងប្រពៃណីវប្បធម៌ចិននោះទេ។ ផ្ទុយទៅវិញ ការជឿព្រះយេស៊ូវ គឺជាការទទួលជឿព្រះយេស៊ូវ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះនៃជីវិតខ្ញុំ ហើយស្វែងយល់អំពីជីវិត តាមទស្សនៈរបស់ព្រះអង្គ។

នៅក្នុងការដើរតាមព្រះ ខ្ញុំនៅតែជាជនជាតិចិន ក្នុងត្រកូលហាក់កា។ ខ្ញុំនៅតែអាចឲ្យតម្លៃ និងគោរពវប្បធម៌ ប្រពៃណី និងឫសគល់របស់ជនជាតិខ្ញុំ លើកលែងតែផ្នែកណា ដែលរារាំងមិនឲ្យខ្ញុំដើរតាមព្រះយេស៊ូវ។



*ទី៥*

## ការគោរពប្រតិបត្តិដល់ឪពុកម្តាយ

*“ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្តាយ ដើម្បីឲ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់ប្រទានឲ្យ”។ និក្ខមនំ ២០:១២*

ព្រះ**គម្ពីរប៊ីបបាននិយាយសង្កត់ធ្ងន់ថា** យើងត្រូវតែស្តាប់បង្គាប់ និងគោរពប្រតិបត្តិចំពោះឪពុកម្តាយយើង។ គឺដូចដែលក្រឹត្យវិន័យទី៥ ក្នុងចំណោមក្រឹត្យវិន័យ១០ប្រការបានបង្គាប់ថា “ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្តាយ ដើម្បីឲ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់ប្រទានឲ្យ” (និក្ខមនំ ២០:១២)។ ក្រឹត្យវិន័យនេះបានចែង បន្ទាប់ពីក្រឹត្យវិន័យទី៤ ដែលបង្គាប់ឲ្យយើងស្រឡាញ់ព្រះ។ ក្នុងគ្រាសញ្ញាថ្មី សាវ័កប៉ុលបានមានប្រសាសន៍ថា “ក្មេងរាល់គ្នាអើយ ចូរស្តាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ដ្បិតធ្វើដូច្នោះទើបបានត្រូវ”(អេភេសូរ ៦:១)។

ព្រះគម្ពីរដើមភាសាហេព្រើរ ប្រើពាក្យ “ខាវេដ” ដែលប្រែមកថា គោរពប្រតិបត្តិ ដែលពាក្យនេះមានន័យថា “ធ្ងន់” ឬ “មានទម្ងន់”។ ដូចនេះ ការគោរពប្រតិបត្តិឪពុកម្តាយ គឺជាការឲ្យតម្លៃដ៏ធ្ងន់ ឬផ្តល់ឲ្យនូវការគោរព ចំពោះមុននាទីរបស់ពួកគាត់ ជាឪពុកម្តាយ។ ព្រះគម្ពីរក៏បានពិពណ៌នាថា ព្រះយេស៊ូវទ្រង់បានគោរពប្រតិបត្តិចំពោះឪពុកម្តាយខាងសាច់ឈាមរបស់ទ្រង់ នៅផែនដី កាលទ្រង់នៅ

ក្មេង ហើយបន្ទាប់ពីទ្រង់បានឃាងបែកពីពួកគេ នៅទីក្រុងយេរូសាឡិម ពួកគេក៏មានការព្រួយបារម្ភពីព្រះអង្គ(លូកា ២:៥១)។ ហើយពេលដែលទ្រង់កំពុងតែជាប់នៅលើឈើឆ្កាង ទ្រង់បានផ្តាំលោកយ៉ូហាន ឲ្យបន្តមើលថែព្រះមាតាទ្រង់(យ៉ូហាន ១៩:២៦)។

បញ្ហាប្រឈមរបស់ខ្ញុំ នៅពេលនោះ គឺត្រូវបន្តគោរពប្រតិបត្តិចំពោះឪពុកម្តាយខ្ញុំ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ជំនឿ ដែលខ្ញុំមានចំពោះព្រះ។ ខ្ញុំក៏បានដឹងថា ខ្ញុំអាចធ្វើដូចនេះបាន ដោយគោរពពួកគាត់ ដោយស្តាប់បង្គាប់ និងថែរក្សាពួកគាត់។ ខ្ញុំមានការលើកទឹកចិត្ត ពេលដែលបានអាន អំពីគំរូរបស់លោកហ្វ្រែនស៊ីស ស្កេហ្វ័រ(Francis Schaeffer) ជាទេវវិទូ ។ ឪពុកម្តាយរបស់គាត់មានការពិបាកចិត្ត ពេលដែលគាត់សម្រេចចិត្តចូលរៀនសាលាព្រះគម្ពីរ។

លោកហ្វ្រែនស៊ីសក៏បានពន្យល់ ដោយការគោរពថា គាត់ជឿថា ព្រះទ្រង់សព្វព្រះទ័យឲ្យគាត់ទៅរៀនសាលាព្រះគម្ពីរ ប៉ុន្តែ គាត់នៅតែបន្តគោរពប្រតិបត្តិចំពោះឪពុកម្តាយគាត់ ដូចដែលព្រះគម្ពីរបានបង្រៀនគាត់។ ទីបន្ទាល់របស់គាត់ពិតជាបានដើរតួរយ៉ាងសំខាន់ នៅក្នុងការនាំអ្នកទាំងពីរឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទនៅពេលក្រោយមកទៀត។

ខ្ញុំបានព្យាយាមអស់ពីសមត្ថភាព នៅក្នុងការអនុវត្តន៍តាម គោលការណ៍នេះក្នុងជីវិតខ្ញុំ។ ពេលដែលម្តាយខ្ញុំបានព្យាយាមបញ្ចុះបញ្ចូលខ្ញុំជាច្រើនដង ឲ្យបោះបង់ជំនឿខ្ញុំចោល ខ្ញុំបានសម្រេចចិត្តថា មិនឆ្លើយតប ឬប្រកែកជាមួយគាត់។ ខ្ញុំក៏បានបង្ហាញចេញនូវការគោរព និងការគួរសម ក្នុងនាមជាកូន។ ខ្ញុំបានជួយការងារផ្ទះ និងជួយដើរទិញឥវ៉ាន់ ពេលណាគាត់ប្រើខ្ញុំ។ កាលពីមុន ខ្ញុំប្រកែកពេលណាពួកគេប្រើខ្ញុំឲ្យធ្វើអ្វីមួយ តែឥឡូវនេះ ខ្ញុំត្រូវប្រាកដថា ខ្ញុំបានធ្វើកិច្ចការទាំងនោះ ដោយស្ម័គ្រពីចិត្ត។

យូរៗម្តង ខ្ញុំបានសួរម៉ាក់ថា “ម៉ាក់ ឃើញទេ? ចាប់តាំងពីពេលដែលកូនក្លាយ



*ខ្ញុំបានតោងឲ្យជាប់ព្រះបន្ទូលសន្យារបស់ព្រះ ដែលសន្យាថា នឹងជួយ និងដឹកនាំខ្ញុំ ហើយព្រះអង្គបានដឹកនាំខ្ញុំ ដោយស្មោះត្រង់ និងជាប់ជានិច្ច។*

ជាគ្រីស្ទាន កូននៅតែជាកូនរបស់ម៉ាក់ ហើយមាក់នៅតែជាម៉ាក់របស់កូន”។

ខ្ញុំក៏នៅបន្តកាន់តាមប្រពៃណីរបស់ជនជាតិចិន ត្រង់ចំណុចណាដែលមិនបានរារាំងខ្ញុំ មិនឲ្យដើរតាមព្រះយេស៊ូវ។ ពេលណាសាច់ញាតិណាម្នាក់លាចាកលោក ខ្ញុំបានជួយធ្វើនេះធ្វើនោះ នៅពិធីបុណ្យសព ហើយបានបង្ហាញចេញនូវការគោរព តាមរបៀបដ៏ត្រឹមត្រូវ។ នៅថ្ងៃខួបនៃការស្លាប់របស់ជីដូនជីតាខ្ញុំ ខ្ញុំក៏បានធ្វើដូចនេះផងដែរ ដោយបានផ្តល់ការគោរព និងនឹកចាំពីពួកគាត់។

ខ្ញុំក៏បានចូលរួមសហគមន៍នៃត្រកូលហាក់ការបស់ប៉ាខ្ញុំ ហើយក៏បានទៅចូលរួមកម្មវិធីសង្គមរបស់សហគមន៍នេះ ឲ្យខានតែបាន។

ទន្ទឹមនឹងនោះ ខ្ញុំបានបន្តជួបជុំជាមួយគ្រីស្ទបរិស័ទដទៃទៀត ហើយអធិស្ឋាន និងអានព្រះគម្ពីរជាទៀងទាត់។ ព្រះជាម្ចាស់បានប្រទានខ្ញុំ នូវកម្លាំងខាងវិញ្ញាណ ដើម្បីស៊ូទ្រាំ ក្នុងជំនឿរបស់ខ្ញុំ ក៏ដូចជាការដឹកនាំ និងប្រាជ្ញា ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ខ្ញុំ ក្នុងអំឡុងពេលដ៏ពិបាកនោះ។ ខ្ញុំបានតោងឲ្យជាប់ព្រះបន្ទូលសន្យារបស់ព្រះ ដែលសន្យាថា នឹងជួយ និងដឹកនាំខ្ញុំ ហើយព្រះអង្គបានដឹកនាំខ្ញុំ ដោយស្មោះត្រង់ និងជាប់ជានិច្ច។

ខ្ញុំជឿថា ព្រះគុណព្រះ បានជួយឲ្យខ្ញុំមានការប្ដេជ្ញាចិត្ត និងដឹកនាំខ្ញុំ ក្នុងការប្រព្រឹត្ត ហើយក៏បានធ្វើឲ្យស្ថានភាពនៅក្នុងផ្ទះ មានភាពល្អប្រសើរឡើង។ ឪពុកម្តាយខ្ញុំមិនបាននិយាយថា ស្ថានភាពក្នុងផ្ទះល្អប្រសើរឡើងទេ តែខ្ញុំអាចមើលដឹងថា ទីបំផុត ពួកគេបានទទួលស្គាល់ការសម្រេចចិត្តរបស់ខ្ញុំ ព្រោះពួកគាត់ឈប់ហាមឃាត់ខ្ញុំ មិនឲ្យទៅព្រះវិហារ ឬទៅទទួលបុណ្យជ្រមុជទឹកនៅពេលក្រោយមកទៀត។ ខ្ញុំក៏បានអរព្រះគុណព្រះសម្រាប់ការបន្ទន់ចិត្តពួកគាត់ ទោះពួកគាត់

មានការប្រឆាំងពីពេលដំបូងក៏ដោយ។

ខ្ញុំក៏បានឃើញភស្តុតាងនៃការផ្លាស់ប្តូរនេះ នៅពេលដែលបងប្អូនភ្លោះរបស់ខ្ញុំក៏បានទទួលជឿព្រះគ្រីស្ទផងដែរ ធ្វើឲ្យខ្ញុំមានអំណរជាពន់ពេក។ ពេលនោះ ប៉ាម៉ាក់ខ្ញុំមិនមានការពិបាកចិត្តខ្លាំង ដូចកាលខ្ញុំទើបតែទទួលជឿព្រះនោះទេ។ មានពេលមួយ ប៉ាខ្ញុំត្រូវបានមិត្តភក្តិគាត់រិះគន់ធ្ងន់ៗ ដោយសារគាត់បណ្តោយឲ្យយើងក្លាយជាគ្រីស្ទាន ហើយមិនបាន “គ្រប់គ្រងគ្រួសាររបស់គាត់ ឲ្យបានត្រឹមត្រូវ”។ ប៉ាដឹងថា ខ្ញុំនិងបងប្អូនភ្លោះខ្ញុំមានការពិបាកចិត្តប៉ុណ្ណា ហើយគាត់ក៏បានកម្សាន្តចិត្តយើង។ គាត់ប្រាប់យើងថា “កុំខ្វល់ពីពួកគេអី។ ពួកគេមិនដឹងថា ខ្លួនឯងកំពុងនិយាយអីទេ”។

យើងមានការភ្ញាក់ផ្អើលមិនតិចទេ ពេលដែលឮគាត់និយាយដូចនេះ។ គាត់មិនបានស្តីបន្ទោសយើង ដែលបានធ្វើឲ្យគាត់បាក់មុខនោះទេ ផ្ទុយទៅវិញ គាត់បានសម្រេចចិត្តការពារយើងវិញ។



ទី៦

# ការរស់នៅ ក្នុងសេចក្ដីសង្ឃឹម និងការទុកចិត្ត

ខ្ញុំបានទទួលជឿព្រះយេស៊ូវ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ អស់រយៈពេលជាច្រើនឆ្នាំហើយ។ ចាប់តាំងពីពេលនោះមក គុណភាពនៃជីវិតថ្មី ដែលព្រះគ្រីស្ទបានប្រទាន គឺជាការផ្លាស់ប្រែដ៏សំខាន់បំផុត ដែលខ្ញុំមាន។ ខ្ញុំនៅជួបបញ្ហាប្រឈមក្នុងជីវិត តែខ្ញុំអាចប្រឈមមុខដោះស្រាយ ដោយជំនួយមកពីព្រះ។ ព្រះអង្គបានប្រទាននូវភាពពេញបរិបូរ ដល់ជីវិតខ្ញុំ ដែលគ្មានអ្វីអាចផ្ដល់ឲ្យបានឡើយ។ ខណៈពេលដែលខ្ញុំរៀនរស់នៅ តាមព្រះបន្ទូលព្រះ និងមានភាពពេញវ័យ ក្នុងទំនាក់ទំនងជាមួយព្រះអង្គ ខ្ញុំក៏បានមានទំនាក់ទំនងកាន់តែស្និទ្ធស្នាល ជាមួយឪពុកម្ដាយ និងបងប្អូនបង្កើតរបស់ខ្ញុំ ហើយទំនាក់ទំនងរបស់ខ្ញុំជាមួយមិត្តភក្តិក៏មានការរីកចម្រើនយ៉ាងខ្លាំង។

ដោយសារខ្ញុំតែងតែដឹងថា ខ្ញុំមានបេសកកម្មធ្វើបន្ទាល់ ដល់ក្រុមគ្រួសារខ្ញុំ នោះខ្ញុំក៏បានឃើញព្រះបន្ទូលសន្យា ក្នុងបទគម្ពីរ កិច្ចការ ១៦:៣១ ក្លាយជាការពិត។ ជាក់ស្ដែង ព្រះជាម្ចាស់បាននាំសមាជិកគ្រួសារខ្ញុំ ចូលមករកព្រះអង្គ តាមរបៀប

ដែលខ្ញុំមិនដែលនឹកស្មានដល់។ ពេលដែលខ្ញុំ និងបងប្អូនភ្លោះរបស់ខ្ញុំ ចាប់ផ្ដើមទៅព្រះវិហារ ឪពុកម្ដាយយើងក៏បានឲ្យបងស្រីច្បងរបស់យើង ទៅតាមឃ្លាំមើលយើង។ ពួកគេមានការមិនទុកចិត្ត ចំពោះក្រុមមនុស្ស ដែលយើងកំពុងតែជួបជុំជាមួយ ហើយភ័យខ្លាចគេនាំយើង ឲ្យក្លាយជាមនុស្សអាក្រក់។ ផ្ទុយទៅវិញ បងស្រីខ្ញុំក៏មានការប៉ះពាល់ចិត្ត ដោយសារការអ្វីដែលគាត់បានឃើញផ្ទាល់ភ្នែកផងដែរ ហើយក្រោយមក គាត់ក៏បានក្លាយជាគ្រីស្ទបរិស័ទ។

ដោយជំនួយមកពីព្រះ ខ្ញុំក៏ចាប់ផ្ដើមយល់ អំពីមូលហេតុ ដែលឪពុកម្ដាយខ្ញុំមិនសប្បាយចិត្ត ពេលខ្ញុំសម្រេចចិត្តដើរតាមព្រះគ្រីស្ទ។ ប៉ាខ្ញុំមិនសប្បាយចិត្ត ព្រោះគាត់ព្រួយបារម្ភពីយើង ហើយខ្លាចការសម្រេចចិត្តរបស់យើង ធ្វើឲ្យបាត់ភាពសុខដុម ក្នុងគ្រួសារ ហើយខ្លាចយើងបាត់បង់សុភមង្គល និងសុវត្ថិភាព។ ខ្ញុំមិនត្រូវមើលឃើញតែការឈឺចាប់ និងការខកចិត្តរបស់ប៉ាម៉ាក់ខ្ញុំនោះឡើយ ហើយត្រូវទទួលស្គាល់ថា ពួកគេរារាំងខ្ញុំ គឺដោយសារពួកគេស្រឡាញ់ខ្ញុំ ពោលគឺ ពួកគេគ្រាន់តែព្យាយាមធ្វើអ្វី ដែលពួកគាត់គិតថា ជាជម្រើសល្អបំផុត សម្រាប់យើង។ ការដឹងដូចនេះ បានជម្រុញចិត្តខ្ញុំ ឲ្យចង់បង្ហាញពួកគាត់ ឲ្យដឹងថា ខ្ញុំចង់អរគុណពួកគេខ្លាំងប៉ុណ្ណា សម្រាប់ការព្រួយបារម្ភរបស់ពួកគាត់។



*ខ្ញុំមិនត្រូវមើលឃើញតែការឈឺចាប់ និងការខកចិត្តរបស់ប៉ាម៉ាក់ខ្ញុំនោះឡើយ ហើយត្រូវទទួលស្គាល់ថា ពួកគេរាំងខ្ញុំ គឺដោយសារពួកគេស្រឡាញ់ខ្ញុំ ...*

ជាការពិតណាស់ ខ្ញុំដឹងថា ពេលនេះ ខ្ញុំអាចស្រឡាញ់ និងគោរពប្រតិបត្តិឪពុកម្ដាយ តាមរបៀប ដែលខ្ញុំមិនដែលនឹកស្មានដល់។ បន្ទាប់ពីបានទទួលព្រះគុណ និងសេចក្តីមេត្តាពីព្រះហើយ ខ្ញុំក៏បានដឹងថា ខ្ញុំត្រូវតែប្រព្រឹត្តដោយព្រះ

គុណ និងក្ដីស្រឡាញ់ ចំពោះអ្នកដទៃផងដែរ។ បន្ទាប់ពីខ្ញុំបានយល់ អំពីការព្រួយបារម្ភ ដែលឪពុកម្ដាយខ្ញុំ មានចំពោះខ្ញុំ ខ្ញុំក៏បានទូលសូមព្រះប្រទាន ក្ដីស្រឡាញ់ និងភាពអត់ធ្មត់ ដើម្បីជួយឲ្យខ្ញុំគោរពប្រតិបត្ដិចំពោះពួកគាត់។

ព្រះអង្គបានជួយខ្ញុំ ក្នុងការទំនាក់ទំនងប្រចាំថ្ងៃ ជាមួយពួកគាត់ ដោយប្រទានឲ្យខ្ញុំមានប្រាជ្ញា ក្នុងការរស់នៅជាស្មរបន្ទាល់របស់ព្រះអង្គ។ ប៉ុន្មានឆ្នាំក្រោយមក ខ្ញុំក៏បានចូលធ្វើការពេញពេល ក្នុងអង្គការគ្រីស្ទបរិស័ទមួយ ហើយឪពុកម្ដាយខ្ញុំមិនបានបដិសេធទេ។ សព្វថ្ងៃនេះ ខ្ញុំបន្តអរសប្បាយ នឹងទំនាក់ទំនងនៃក្ដីស្រឡាញ់ ដ៏ជិតស្និទ្ធជាមួយពួកគាត់។

ទន្ទឹមនឹងនោះ ខ្ញុំបានបន្តសង្ឃឹម អធិស្ឋាន និងទុកចិត្តព្រះអម្ចាស់ថា ថ្ងៃមួយពួកគាត់នឹងបានស្គាល់ ហើយថ្វាយបង្គំព្រះគ្រីស្ទ ដែលមានតែព្រះអង្គទេ ដែលជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ នៃពិភពលោក។

# សេចក្តីបន្ថែមចុងក្រោយ

## តើអ្នកត្រូវធ្វើដូចម្តេច ពេលដែលគ្រួសាររបស់អ្នកបដិសេធន៍?

តើអ្នកធ្លាប់ជួបបញ្ហាស្រដៀងនេះទេ? តើក្រុមគ្រួសារអ្នក មានការប្រឆាំង មកលើជំនឿរបស់អ្នកឬទេ ហើយអ្នកមានការពិបាក នៅក្នុងការបន្តជឿលើព្រះគ្រីស្ទឬទេ? សូមអនុញ្ញាតឲ្យខ្ញុំលើកទឹកចិត្តអ្នក តាមបទពិសោធន៍របស់ខ្ញុំ ដូចតទៅ :

## តោងឲ្យជាប់សេចក្តីពិត

បទគម្ពីរកិច្ចការ ៤:១២ បានលើកឡើង អំពីសេចក្តីពិតរបស់ព្រះជាម្ចាស់ តាមរបៀបដ៏សាមញ្ញ និងមានអំណាចថា : “គ្មានសេចក្តីសង្រ្គោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្រ្គោះនោះឡើយ”។ ពេលណាយើងសម្រេចចិត្តដើរតាមព្រះយេស៊ូវ គឺយើងមិនគ្រាន់តែសម្រេចចិត្តថា យើងនឹងស្មោះស្ម័គ្រចំពោះព្រះមួយអង្គ ដែលយើងបានជ្រើសរើស បានសេចក្តីថា យើងកំពុងតែងាកបែរទៅរកព្រះពិតតែមួយ ព្រះនាមយេស៊ូវ។ ព្រះអង្គបានផ្សះផ្សារយើងឲ្យជានឹងព្រះវរបិតា ហើយបើកផ្លូវឲ្យយើងអាចចូលទៅក្នុងការប្រកបដ៏អស់កល្បជាមួយព្រះអង្គ។ ក្នុងបទគម្ពីរ យ៉ូហាន ១៤:៦ ព្រះយេស៊ូវមានបន្ទូលថា “ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ”។

## ធ្វើជាអ្នកនាំផ្លូវ សម្រាប់គ្រួសារអ្នក

បទគម្ពីរលូកា ៦:៣៩ បានចែងថា “តើមនុស្សខ្វាក់អាចនឹងដឹកមនុស្សខ្វាក់បានឬទេ តើមិនធ្លាក់ទៅក្នុងរណ្តៅទាំង២នាក់ទេឬអី?” បទគម្ពីរនេះបានរំឮកយើងថា

យើងចំបាច់ត្រូវជ្រើសរើសផ្លូវដ៏ត្រឹមត្រូវ ក្នុងជីវិត។ បន្ទាប់ពីយើងបានរកឃើញផ្លូវតែមួយ ឆ្ពោះទៅរកព្រះហើយ នោះយើងអាចដឹកនាំមនុស្សជាទីស្រឡាញ់របស់យើង ទៅរកព្រះអង្គ តាមរយៈព្រះយេស៊ូវ។ ប៉ុន្តែ ការនេះត្រូវការពេលវេលា និងភាពអត់ធ្មត់។ បើអ្នកជាមនុស្សទីមួយក្នុងគ្រួសារ ដែលងាកបែរទៅរកព្រះគ្រីស្ទ នោះចូរមានសង្ឃឹមឡើង ដ្បិតដំណឹងល្អបានចាក់ឫសចូលក្នុងគ្រួសារអ្នក តាមរយៈអ្នកហើយ។ ចូរអនុញ្ញាតឲ្យព្រះទ្រង់ធ្វើការ ក្នុងចិត្តមនុស្សជាទីស្រឡាញ់របស់អ្នក ហើយបង្ហាញពួកគេ នូវសេចក្តីស្រឡាញ់របស់ព្រះអង្គ តាមរយៈការទំនាក់ទំនងជាមួយពួកគេរៀងរាល់ថ្ងៃ។

## ចូរគោរពប្រតិបត្តិឪពុកម្តាយរបស់អ្នក

បទគម្ពីរអេភេសូរ ៦:១ បានថែងថា “ក្មេងរាល់គ្នាអើយ ចូរស្តាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ដ្បិតធ្វើដូច្នោះទើបបានត្រូវ”។ ព្រះគម្ពីរប៊ីបបានបញ្ជាក់ច្បាស់ថា យើងត្រូវគោរពប្រតិបត្តិឪពុកម្តាយរបស់យើង ទោះពួកគាត់មានជំនឿខុសពីយើង ហើយនិយាយដូចម្តេច អំពីជំនឿរបស់យើងក៏ដោយ។ ការធ្វើដូចនេះមិនគ្រាន់តែជាការស្តាប់បង្គាប់ប៉ុណ្ណោះទេ តែជាការឆាប់យល់អារម្មណ៍របស់ពួកគាត់ ដោយឲ្យតម្លៃ ចំពោះអ្វីដែលសំខាន់ចំពោះពួកគាត់ ហើយគោរពពួកគាត់ដោយចាត់ទុកពួកគាត់ជាមនុស្សសំខាន់ក្នុងជីវិតអ្នក។ យើងត្រូវយកព្រះជាទីមួយក្នុងជីវិតអ្នក ប៉ុន្តែ អ្នកត្រូវបញ្ជាក់ឲ្យឪពុកម្តាយអ្នកដឹងថា ពួកគាត់នៅតែសំខាន់ចំពោះអ្នក ហើយបង្ហាញពួកគាត់ថា អ្នកនឹងបំពេញតួនាទីជាកូនល្អ ដោយផ្គត់ផ្គង់និងថែរក្សាពួកគាត់។ ការនេះស្ថិតក្នុងចំណោមវិធីសាស្ត្រដែលមានប្រសិទ្ធិភាពបំផុត ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ព្រះ។

## ស្វែងរកជំនួយខាងវិញ្ញាណ

ព្រះទ្រង់មិនបានត្រាស់ហៅអ្នក ឲ្យធ្វើដំណើរខាងវិញ្ញាណតែម្នាក់ឯងនោះទេ។ ចូរបន្តជួបជុំបងប្អូនរួមជំនឿរបស់អ្នក ដែលអាចទ្រទ្រង់អ្នក ទាំងផ្លូវវិញ្ញាណ និងផ្លូវចិត្ត។ ពួកគេអាចអធិស្ឋានជាមួយអ្នក លើកទឹកចិត្ត និងកម្សាន្តចិត្តអ្នក ក្នុងពេលដ៏ពិបាក ហើយអាចផ្តល់យោបល ឬស្តាប់អ្នករៀបរាប់ អំពីបញ្ហារបស់អ្នក។ ព្រះគម្ពីរប៊ីបបានផ្តល់ឲ្យយើង នូវគំរូនៃមនុស្សអស្ចារ្យជាច្រើននាក់ រាប់ចាប់តាំងពីស្តេចដាវីឌ ដល់សាវ័កប៉ុល ដែលមិនមានការភ័យខ្លាច នៅក្នុងការស្វែងរកការកម្សាន្តចិត្ត ពីបងប្អូនរួមជំនឿរបស់ពួកគេ។ ជាការពិតណាស់ ចូរបន្តការប្រកបស្និទ្ធស្នាលជាមួយព្រះ ដោយនិយាយទៅកាន់ព្រះអង្គជាប្រចាំ ហើយស្វែងរកកម្លាំង និងប្រាជ្ញា ក្នុងព្រះបន្ទូលទ្រង់។

# ក្រុមសៀវភៅការរុករកឃើញ

*ការងារបេសកកម្មរបស់យើងខ្ញុំ គឺដើម្បីឲ្យមនុស្សគ្រប់រូបមានឱកាសទទួល និងមានការយល់ដឹងអំពីប្រាជ្ញានៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ ។*

ក្រុមសៀវភៅការរុករកឃើញ បកស្រាយអំពីសេចក្ដីពិតនៃព្រះយេស៊ូវគ្រីស្ទ ដល់លោកិយ ដោយប្រើធនធានដែលមានតុល្យភាព ដែលគួរឲ្យចាប់អារម្មណ៍ និងអាចរកបាន ដែលបង្ហាញថា ព្រះគម្ពីរមានសារៈសំខាន់បំផុត ចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិត។ កូនសៀវភៅ នៅក្នុងក្រុមសៀវភៅការរុករកឃើញ គឺអាចរកបាន ដោយឥតគិតថ្លៃ ហើយអាចត្រូវបានប្រើសម្រាប់ការសិក្សាផ្ទាល់ខ្លួន ក្នុងក្រុមតូច ឬក្នុងការងារឈោងចាប់។

យើងខ្ញុំសូមអរគុណ សម្រាប់ការគាំទ្រធនធានរបស់ក្រុមសៀវភៅការរុករកឃើញ និងអង្គការនំម៉ាណាប្រចាំថ្ងៃ។ មានគ្រីស្ទបរិស័ទជាច្រើនបានរួមចំណែកក្នុងការដាក់ដង្វាយឧបត្ថម្ភ ទោះតិចតួច ឬច្រើនក្ដី ដល់អង្គការនំម៉ាណាប្រចាំថ្ងៃ ដើម្បីឲ្យឈោងចាប់អ្នកដទៃ ដោយប្រាជ្ញានៃព្រះគម្ពីរដែលធ្វើឲ្យជីវិតផ្លាស់ប្រែ។ យើងខ្ញុំមិនបានទទួលប្រាក់ជំនួយពីក្រុម ឬនិកាយណាមួយឡើយ។or

CLICK TO DONATE